ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# តំបន់ឧស្សាហកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងបង្កើត និងគ្រប់គ្រងតំបន់ឧស្សាហកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមលើកស្ទួយសេដ្ឋកិច្ចជាតិ តាមរយៈការអភិវឌ្ឍវិស័យឧស្សាហកម្មប្រកបដោយចិរភាព ។

**មាត្រា ២.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់ លើតំបន់ឧស្សាហកម្មទាំងអស់ នៅលើទឹកដីនៃ ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម និងអ្នកវិនិយោគក្នុងតំបន់ឧស្សាហកម្ម ដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រងទាំងអស់ ត្រូវស្ថិតនៅក្រោមច្បាប់នេះហើយអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ។

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម គឺជាអ្នកបង្កើតតំបន់ឧស្សាហកម្ម ដោយសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ស្របតាមប្លង់មេរបស់តំបន់ឧស្សាហកម្ម និង អាចជាអ្នកទទួលសិទ្ធិស្របច្បាប់ក្នុងការអភិវឌ្ឍតំបន់ ឧស្សាហកម្ម ក្រោយការបង្កើតតំបន់ឧស្សាហកម្ម ។

អ្នកវិនិយោគក្នុងតំបន់ឧស្សាហកម្ម គឺជាអ្នកបង្កើតរោងចក្រ សហគ្រាស អាគារ ឬ/និង ធ្វើផលិតកម្ម អាជីវកម្ម និងសេវាកម្មក្នុងតំបន់ឧស្សាហកម្ម ។

**មាត្រា ៤.-**

តំបន់ឧស្សាហកម្ម គឺជាតំបន់ពិសេសសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម ដែលប្រមូលផ្តុំសកម្មភាព ឧស្សាហកម្ម និងសកម្មភាពពាក់ព័ន្ធដទៃទៀត

ហើយដែលអាចមានតំបន់ឧស្សាហកម្មទូទៅ ឬ/និង តំបន់ផលិត ផលកែច្នៃនាំចេញ ។ តំបន់ឧស្សាហកម្មនីមួយៗ ត្រូវមានមណ្ឌលផលិតកម្ម និងអាចមានមណ្ឌលពាណិជ្ជកម្មសេរី មណ្ឌលសេវាកម្ម និងមណ្ឌលលំនៅឋាន ។

**តំបន់ឧស្សាហកម្មទូទៅ** គឺជាតំបន់មួយដែលសង់ឡើងសម្រាប់សកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀត ដែលពាក់ព័ន្ធនឹងការផលិតទំនិញសម្រាប់បម្រើសេចក្តីត្រូវការក្នុងប្រទេស ឬ/និង សម្រាប់នាំចេញ ។

**តំបន់ផលិតកែច្នៃនាំចេញ** គឺជាតំបន់នៃសកម្មភាពឧស្សាហកម្ម និងសកម្មភាពដទៃទៀត ដែលពាក់ព័ន្ធនឹងការផលិតទំនិញសម្រាប់បម្រើតែការនាំចេញប៉ុណ្ណោះ ។

**មណ្ឌលផលិតកម្ម** គឺជាមណ្ឌលប្រមូលផ្តុំរោងចក្រដែលស្ថិតនៅក្នុងតំបន់ឧស្សាហកម្ម ។

**មណ្ឌលពាណិជ្ជកម្មសេរី** គឺជាមណ្ឌលរួចពន្ធ ដែលស្ថិតនៅក្នុងតំបន់ឧស្សាហកម្មសម្រាប់សកម្មភាពផ្គត់ផ្គង់ ស្តុក ដាក់តាំង វេចខ្ចប់ សំអាត ឬបង្ហើយការនូវផលិតផលសម្ភារៈ បរិក្ខារ ឬសម្ភារៈដទៃទៀតដែលមិនមានការហាមឃាត់ដោយច្បាប់ សម្រាប់បម្រើឱ្យសកម្មភាពឧស្សាហកម្ម ។

**មណ្ឌលសេវាកម្ម** គឺជាមណ្ឌលសម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម និងពាណិជ្ជកម្ម ដូចជាការិយាល័យចាត់ចែង និងប្រតិបត្តិការរបស់តំបន់ឧស្សាហកម្ម ធនាគារ ប្រៃសណីយ៍ មជ្ឈមណ្ឌលបណ្តុះបណ្តាល អាគារលក់ទំនិញប្រចាំថ្ងៃ និងមធ្យោបាយនានាផ្សេងៗទៀត ដែលស្ថិតនៅក្នុងតំបន់ឧស្សាហកម្ម ។

**មណ្ឌលលំនៅឋាន** គឺជាមណ្ឌលសម្រាប់ការស្នាក់អាស្រ័យរបស់និយោជក និងនិយោជិត និងកម្មករ ក្នុងតំបន់ឧស្សាហកម្ម ។

**មាត្រា ៥.-**

តំបន់ផលិតកែច្នៃនាំចេញ និងមណ្ឌលពាណិជ្ជកម្មសេរី ត្រូវការពារដោយហ៊ុំព័ទ្ធរបង ដែលមានការត្រួតពិនិត្យតាមច្រកចេញចូល ។

## ជំពូកទី ២

## រចនាសម្ព័ន្ធគ្រប់គ្រងតំបន់ឧស្សាហកម្ម

**មាត្រា ៦.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញ-ចូលតែមួយគត់ក្នុងការទទួលបន្ទុកការគ្រប់គ្រង ការអភិវឌ្ឍ ការវិនិយោគ និងកិច្ចដំណើរការតំបន់ឧស្សាហកម្ម ។

**មាត្រា ៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅដែលទាក់ទងដល់រាល់ការសម្រេចអនុម័តឱ្យបង្កើត ការគ្រប់គ្រង ត្រួតពិនិត្យឧស្សាហកម្ម ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅ នៃរដ្ឋបាលតំបន់ឧស្សាហកម្ម ត្រូវកំណត់ដោយ

អនុក្រឹត្យ ។

**មាត្រា ៨.-**

**រដ្ឋបាលតំបន់ឧស្សាហកម្ម** ជាអង្គការគ្រប់គ្រងរដ្ឋបាល និងជាយន្តការ **ច្រកចេញ-ចូលតែមួយនៅនឹងកន្លែង** របស់តំបន់ឧស្សាហកម្ម ។

រដ្ឋបាលតំបន់ឧស្សាហកម្ម មានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃ និងជាអ្នកសំរបសំរួលរាល់កិច្ចការ ដើម្បីជំរុញល្បឿននៃការដោះស្រាយតម្រូវការវិនិយោគ ក្នុងតំបន់ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់ ។

## ជំពូកទី ៣

## ការបង្កើតតំបន់ឧស្សាហកម្ម

**មាត្រា ៩.-**

ការបង្កើតតំបន់ឧស្សាហកម្មនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែកពីគ្នាដែលមានបញ្ជាក់ពីទីតាំង ព្រំប្រទល់ ភូមិសាស្ត្រ ទំហំ វិសាលភាពនៃកិច្ចប្រតិបត្តិការ ការគ្រប់គ្រង និងការបង្កើតរដ្ឋបាលតំបន់ឧស្សាហកម្ម តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ១០.-**

តំបន់ឧស្សាហកម្មអាចបង្កើតឡើងតាមរូបភាពជាក្រុមហ៊ុនរដ្ឋ រដ្ឋចម្រុះឯកជន ឬឯកជន ។

**មាត្រា ១១.-**

កម្មសិទ្ធិឯកជនស្របច្បាប់ និងសិទ្ធិផ្សេងៗទៀតដែលទទួលស្គាល់ដោយច្បាប់ ដែលស្ថិតនៅក្នុងគម្រោងបង្កើត ឬពង្រីកតំបន់ឧស្សាហកម្ម និងសម្រាប់ធ្វើជាហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ទៅនឹងតំបន់ឧស្សាហកម្ម ត្រូវធ្វើការទូទាត់ជាមុន ដោយតម្លៃសមរម្យ និងយុត្តធម៌ មុននឹងចេញការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតតំបន់ឧស្សាហកម្ម ។

**មាត្រា ១២.-**

ម្ចាស់សំណង់ខុសច្បាប់ទាំងឡាយក្នុងតំបន់ ដែលត្រូវកំណត់ជាតំបន់ឧស្សាហកម្មត្រូវរុះរើសំណង់ក្នុងរយៈពេល ០៣(បី)ខែ ដោយគ្មានសំណង គិតចាប់ពីថ្ងៃចេញអនុក្រឹត្យស្តីពីការបង្កើតតំបន់ឧស្សាហកម្មនោះ ។

**មាត្រា ១៣.-**

សំណង់ក្នុងតំបន់ឧស្សាហកម្មត្រូវអនុវត្ត ស្របទៅតាមប្លង់មេរបស់តំបន់ឧស្សាហកម្ម ដែលបានអនុម័តរួចដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ចំពោះសំណង់ណាដែលបាន និងកំពុងសាងសង់ដោយគ្មានការអនុញ្ញាត ឬមិនស្របតាមប្លង់មេ ឬប្រាស ចាកលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតសាងសង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវជូនដំណឹងក្នុងរយៈពេល មួយសមស្របដល់ម្ចាស់សំណង់ អោយផ្អាកការសាងសង់ និងធ្វើការកែប្រែ ឬរុះរើសំណង់ទាំងមូល ឬផ្នែកណា មួយក្នុងរយៈពេលមួយដែលកំណត់ក្នុងសេចក្តីជូនដំណឹងនោះ ។

ក្រោយរយៈពេលកំណត់ បើម្ចាស់សំណង់ពុំអនុវត្តតាមសេចក្តីជូនដំណឹង របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជាទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិធ្វើការកែប្រែ ឬសម្រេចរុះរើសំណង់ទាំងមូល ឬផ្នែកណាមួយ ដោយតម្រូវអោយម្ចាស់សំណង់ចេញសោហ៊ុយចំណាយទាំងស្រុង ។

**មាត្រា ១៤.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាគោលការណ៍លើការកំណត់តំបន់ និងការ លើកទឹកចិត្តចាំបាច់ ក្នុងការបង្កើតតំបន់ឧស្សាហកម្ម ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា ត្រូវផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬលិខិតបដិសេធជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃចាប់ពីថ្ងៃដែលដាក់ពាក្យសុំត្រឹមត្រូវ និងគ្រប់គ្រាន់ ដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ក្នុង ករណីបដិសេធ ។

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ដែលបានទទួលលិខិតអនុញ្ញាតជាគោលការណ៍ត្រូវដាក់ជូនក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា នូវគម្រោងលម្អិតនៃតំបន់ឧស្សាហកម្មដែលរួមមាន ប្លង់មេ គម្រោង សិក្សាសមិទ្ធិលទ្ធភាព សេដ្ឋកិច្ច និងស្ថានភាពហិរញ្ញវត្ថុ ក្នុងរយៈពេលកំណត់មួយគិតចាប់តាំងពីថ្ងៃចេញលិខិតអនុញ្ញាតជាគោល ការណ៍។ ក្នុងករណីគម្រោងលម្អិតនៃតំបន់ឧស្សាហកម្មមានលក្ខណៈគ្រប់គ្រាន់ អនុក្រឹត្យ ស្តីពីការបង្កើតតំបន់ ឧស្សាហកម្ម ត្រូវចេញជូនអ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ក្នុងរយៈពេល ១០០(មួយរយ) ថ្ងៃ គិតចាប់ពីថ្ងៃដាក់ គម្រោងលម្អិត នៃតំបន់ឧស្សាហកម្មនោះ ។

## ជំពូកទី ៤
## កិច្ចដំណើរការ

**មាត្រា ១៥.-**

រាល់កិច្ចការរដ្ឋបាល និងបែបបទគតិយុត្តិនៅក្នុងតំបន់ឧស្សាហកម្ម ត្រូវស្ថិតនៅក្រោមរដ្ឋបាលតំបន់ ឧស្សាហកម្មនោះ ដូចមានចែងក្នុងមាត្រា៧នៃច្បាប់នេះ លើកលែងតែការងារបច្ចេកទេសទាក់ទងដល់កិច្ចដំណើរ ការរបស់គ្រឹះស្ថានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងគ្រឹះស្ថានធានារ៉ាប់រង ក្នុងតំបន់ឧស្សាហកម្មដែលត្រូវស្ថិតនៅ ក្រោមច្បាប់ និងបទប្បញ្ញត្តិដោយឡែក ។

**មាត្រា ១៦.-**

ការនាំចូលពីបរទេសទៅក្នុងតំបន់ឧស្សាហកម្ម ឬការនាំចេញពីតំបន់ឧស្សាហកម្មទៅបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់រដ្ឋបាលតំបន់ឧស្សាហកម្ម ស្របតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ។

ទំនិញដែលធ្វើការផ្លាស់ប្តូរតាមគ្រប់រូបភាពរវាងសហគ្រាស រោងចក្រ នៅក្នុងតំបន់ឧស្សាហកម្មមួយ ជាមួយតំបន់ឧស្សាហកម្មមួយទៀត ត្រូវមានការអនុញ្ញាតពីរដ្ឋបាលតំបន់ឧស្សាហកម្ម ដែលពាក់ព័ន្ធ ។

**មាត្រា ១៧.-**

ទំនិញដែលនាំចេញពីដែនគយនៃព្រះរាជាណាចក្រកម្ពុជា ចូលទៅក្នុងតំបន់ឧស្សាហកម្ម ត្រូវចាត់ទុកថា បាននាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយត្រូវជាប់ពន្ធអាករខាងការនាំចេញ និងកំរិតកំណត់នានាស្របតាម ច្បាប់ជាធរមាន ។

ទំនិញដែលនាំចេញពីតំបន់ឧស្សាហកម្ម ចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា បាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវជាប់ពន្ធអាករនៃការនាំចូល និងកម្រិតកំណត់នានាស្របតាមច្បាប់ជាធរមាន ។

**មាត្រា ១៨.-**

ដីឡូតិ៍ក្នុងតំបន់ឧស្សាហកម្ម ត្រូវធ្វើការអភិវឌ្ឍ ស្របទៅតាមពេលវេលាដែលបានកំណត់ក្នុងកម្មវិធីអភិវឌ្ឍ និងស្របតាមប្លង់មេនៃតំបន់ឧស្សាហកម្ម ។

**មាត្រា ១៩.-**

មានតែរដ្ឋបាលតំបន់ឧស្សាហកម្ម ភ្នាក់ងារមានសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ដែលមានសិទ្ធិប្រើប្រាស់ឈ្មោះដែលមានន័យ ឬអានថា **"តំបន់ឧស្សាហកម្ម" "តំបន់ ឧស្សាហកម្មទូទៅ" "តំបន់ផលិតកែច្នៃនាំចេញ" "មណ្ឌលផលិតកម្ម" "មណ្ឌលពាណិជ្ជកម្មសេរី"** ឬ **"មណ្ឌលសេវា កម្ម"** នៅលើត្រា ផ្លាកសញ្ញា លិខិត សេចក្តីជូលដំណឹង ឬឯកសារផ្សេងៗដែលទាក់ទងនឹងតំបន់ឧស្សាហកម្ម ។

## ជំពូកទី ៥

## ការលើកទឹកចិត្ត

**មាត្រា ២០.-**

គម្រោងអភិវឌ្ឍតំបន់ឧស្សាហកម្ម និងគម្រោងវិនិយោគក្នុងតំបន់ឧស្សាហកម្ម ត្រូវបានទទួលសិទ្ធិបុព្វសិទ្ធិ និងការលើកទឹកចិត្តនានា លុះត្រាតែគម្រោងទាំងនេះ ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់

គ្រាន់ ដូចមានចែងក្នុងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ជាធរមាន ។ ដោយឡែក គម្រោងអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម ត្រូវបានទទួលការលើកទឹកចិត្តដូចមានចែងក្នុងជំពូកទី៥ ផ្នែកទី១ មាត្រា ២២ នៃច្បាប់នេះ ។ សិទ្ធិ បុព្វសិទ្ធិ និងការលើកទឹកចិត្តនានាដែលគម្រោងអភិវឌ្ឍតំបន់ឧស្សាហកម្ម និងគម្រោង វិនិយោគក្នុងតំបន់ឧស្សាហកម្មទទួលបាន មិនអាចផ្ទេរ ឬប្រគល់ឱ្យតតិយជនណាមួយបានឡើយ លើកលែងតែក្នុង ករណីទិញ ឬរំលាយបញ្ចូលគ្នា ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ២១.-**

ទន្ទឹមនឹងការប្រើប្រាស់ប្រាក់រៀល រូបិយប័ណ្ណបរទេស អាចធ្វើចរាចរដោយសេរី នៅក្នុងតំបន់ឧស្សាហកម្ម។

## ផ្នែកទី ១

## ការលើកទឹកចិត្តសម្រាប់គម្រោងអភិវឌ្ឍន៍តំបន់ឧស្សាហកម្ម

**មាត្រា ២២.-**

គម្រោងអភិវឌ្ឍតំបន់ឧស្សាហកម្ម ត្រូវបានទទួលការលើកទឹកចិត្តលើពន្ធគយ និងអាករ ដូចខាងក្រោម៖

- រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញសម្រាប់គម្រោងអភិវឌ្ឍតំបន់ឧស្សាហកម្ម ត្រូវស្មើនឹង រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ របស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យដាំដុះរយៈពេលវែង ។
- លើកលែងទាំងស្រុង ឬលើកលែងជាភាគលើពន្ធគយ និងអាករសម្រាប់ការនាំចូលគ្រឿងម៉ាស៊ីន ឧបករណ៍ គ្រឿងចក្រ គ្រឿងបន្លាស់នានា សម្ភារៈសំណង់ ដែលជាទ្រព្យរូបីរបស់ក្រុមហ៊ុនសម្រាប់ បម្រើការងារ នៅក្នុងការបង្កើនតំបន់ឧស្សាហកម្ម ។
- ទ្រព្យរូបីទាំងឡាយរបស់អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ដែលបាននាំចូលក្រោមការលើកលែងទាំងស្រុង ឬការលើកលែងជាភាគនូវពន្ធ និងអាករ ក្រោយមកបានលក់ ផ្ទេរ បង្វែរ យកទៅប្រើប្រាស់ខុសពីទិសដៅបានអនុញ្ញាតត្រូវជាប់ពន្ធ និងអាករតាមសភាពជាក់ស្តែងនៃទ្រព្យរូបី ដែលបានលក់ ផ្ទេរ បង្វែរទាំងនោះ ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ។

## ផ្នែកទី ២

## ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគ ក្នុងតំបន់ឧស្សាហកម្ម

**មាត្រា ២៣.-**

គម្រោងវិនិយោគក្នុងតំបន់ត្រូវបានចាត់ទុកថា ជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រូវបានទទួលការលើកទឹកចិត្តលើពន្ធគយ និងពន្ធអាករ ដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដទៃទៀត ដែលមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀតជាធរមាន ។ គ្រឿងម៉ាស៊ីន ឧបករណ៍ គ្រឿងចក្រ គ្រឿងបន្លាស់នានា សម្ភារៈសំណង់ វត្ថុធាតុដើម ដែលជាទ្រព្យរូបីហើយបាននាំចូលក្នុងតំបន់ឧស្សាហកម្មក្រោមការលើកលែងទាំងស្រុង ឬការលើកលែងជាភាគ នូវពន្ធគយ និងអាករ ក្រោយមកបានយកទៅប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ត្រូវចាត់ទុកជាការនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវបំពេញបែបបទ និងបង់ពន្ធគយ និងអាករគ្រប់ប្រភេទឡើងវិញស្របតាមច្បាប់ជាធរមាន ។

**មាត្រា ២៤.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្មអាចស្នើសុំដីសម្បទាន ពីរដ្ឋសម្រាប់បង្កើតតំបន់ឧស្សាហកម្មរហូតដល់រយៈពេល ៩៤ (កៅសិបប្រាំបួន) ឆ្នាំ ហើយអាចជួលបន្តឱ្យអ្នកវិនិយោគក្នុងតំបន់ឧស្សាហកម្ម ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកអភិវឌ្ឍមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

## ផ្នែកទី ៣

## ការលើកទឹកចិត្តលើការប្រើប្រាស់កំលាំងពលកម្ម

**មាត្រា ២៥.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម និងអ្នកវិនិយោគក្នុងតំបន់ឧស្សាហកម្មអាចជ្រើសរើសពលករកម្ពុជាដោយខ្លួនឯងបាន ។

ប្រៀវត្សរ ឬកម្រៃពលកម្ម ឬលាភការនៃពលករកម្ពុជា ត្រូវកំណត់តាមរយៈកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន ។

**មាត្រា ២៦.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម និងអ្នកវិនិយោគក្នុងតំបន់ឧស្សាហកម្ម មានសិទ្ធិនាំមកជាមួយនូវសហព័ទ្ធ និងអ្នកក្នុងបន្ទុករបស់ខ្លួន និងមានសិទ្ធិធ្វើការជ្រើសរើសនិយោជិត និងកម្មករបរទេសបាន ដោយផ្អែកលើមូលដ្ឋានច្បាប់ការងារ និងច្បាប់អន្តោប្រវេសន្តនៃព្រះរាជាណាចក្រកម្ពុជា ។

និយោជិតបរទេស ត្រូវបានអនុញ្ញាតឱ្យផ្ទេរទៅក្រៅប្រទេស នូវប្រាក់បៀវត្សរ៍ដែលទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ឬដោយវិធានការស្របច្បាប់ដទៃទៀតក្រោយពីបានបង់ពន្ធ រួច ។

## ជំពូកទី ៦
## អធិការកិច្ចក្នុងតំបន់ឧស្សាហកម្ម

**មាត្រា ២៧.-**

មន្ត្រីមានសមត្ថកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលមានភារកិច្ចធ្វើអធិការកិច្ចមានសិទ្ធិចូលក្នុងបរិវេណផលិតកម្ម ឬសេវាកម្មក្នុងតំបន់ឧស្សាហកម្ម នៅក្នុងពេលម៉ោងធ្វើការដើម្បីសាកសួរព័ត៌មាន ស្រាវជ្រាវឯកសារ ឬការណ៍ផ្សេងៗទៀតដែលពាក់ព័ន្ធនៅក្នុងបរិវេណនោះស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា យ៉ាងតិចបានមុន ២៤ (ម្ភៃបួន) ម៉ោង លើកលែងតែករណីចាំបាច់ និងជាបន្ទាន់ដែលនាយករដ្ឋបាលតំបន់ឧស្សាហកម្ម ត្រូវបានទទួលសិទ្ធិឱ្យចេញការជូនដំណឹងដូចគ្នានេះ ។

**មាត្រា ២៨.-**

រដ្ឋបាលតំបន់ឧស្សាហកម្ម អាចត្រួតពិនិត្យរោងចក្រ អាគារ មធ្យោបាយដឹកជញ្ជូន មនុស្ស សម្ភារៈ បរិក្ខារ វត្ថុធាតុដើម សំណល់ និងទំនិញនៅក្នុងតំបន់ឧស្សាហកម្ម ដោយអនុលោមទៅតាមបទប្បញ្ញត្តិទាំងឡាយដែលកំណត់ដោយច្បាប់នេះ ឬ/និង បទប្បញ្ញត្តិដទៃទៀតជាធរមាន ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

អ្នកអភិវឌ្ឍតំបន់ឧស្សាហកម្ម ឬអ្នកទទួលសិទ្ធិស្របច្បាប់ក្នុងការអភិវឌ្ឍតំបន់ឧស្សាហកម្ម ដែលបាននិងកំពុងធ្វើសកម្មភាពនៅមុនថ្ងៃ ឬនៅថ្ងៃច្បាប់នេះចូលជាធរមាន ត្រូវទទួលបាននូវផលប្រយោជន៍ សិទ្ធិ បុព្វសិទ្ធិ និងការលើកទឹកចិត្តនានាដូចមានចែងក្នុងច្បាប់នេះដែរ ក្រោយពេលបានបំពេញបែបបទបង្កើតតំបន់ឧស្សាហកម្មនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៣០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃ ........... ខែ........... ឆ្នាំ............
នាសម័យប្រជុំរដ្ឋសភា លើកទី....... នីតិកាលទី...... ។

រាជធានីភ្នំពេញ, ថ្ងៃទី........... ខែ.......... ឆ្នាំ..........

**ប្រធានរដ្ឋសភា**

**នរោត្តម រណឫទ្ធិ**